រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

036KH01A-01

ក្រុមជំនុំ និង សង្គម



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៣៦

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ជួយសមាជិកគ្រប់រូបរបស់ក្រុមជំនុំអ្នក អោយចេះជួយអ្នកដែលខ្វះខាត ដោយសេចក្តីស្រឡាញ់ ។

កិច្ចការបំរើពីរយ៉ាងរបស់ក្រុមជំនុំចំពោះពិភពលោក

កិច្ចការបំរើធំៗពីរយ៉ាងរបស់ក្រុមជំនុំចំពោះមនុស្ស គឺ :

- ជួយពួកគេអោយក្លាយជាសាវ័ករបស់ព្រះគ្រីស្ត ។
- បំរើពួកគេដោយសេចក្តីស្រឡាញ់ ។

ក្រុមជំនុំដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត មិនមែនគ្រាន់តែប្រកាសដំណឹងល្អ ដោយពាក្យសំដីទេ តែចេះអនុវត្តតាមព្រះបន្ទូលទៀតផង (១ កូរិនថូស ១៣:១) ។

១ យ៉ូហាន ៤:២០-២១ ចែងថា÷ *«បើនរណាម្នាក់ពោលថា "ខ្ញុំស្រឡាញ់ព្រះជាម្ចាស់" តែស្អប់បងប្អូនរបស់ខ្លួន អ្នកនោះនិយាយកុហកហើយ ។ អ្នកណាមិនស្រឡាញ់បងប្អូនដែលខ្លួនមើលឃើញ ក៏ពុំអាចស្រឡាញ់ព្រះជាម្ចាស់ ដែលខ្លួនមើលពុំឃើញនោះបានដែរ ។ យើងបានទទួលវិន័យនេះពីព្រះអង្គថា "អ្នកណាស្រឡាញ់ព្រះជាម្ចាស់ អ្នកនោះក៏ត្រូវស្រឡាញ់បងប្អូនដែរ" »* ។

កំណត់ចំណាំ :

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- ពន្យល់ប្រាប់ក្រុមជំនុំរបស់អ្នក អំពីមូលហេតុដែលបណ្តាលអោយមានភាពក្រខ្សត់ និង អំពីឥទ្ធិពលល្អនៃការកែប្រែចិត្តគំនិតពិតប្រាកដលើសហគមន៍ ។
- បង្រៀនអំពីរបៀប ដែលពួកគ្រីស្តជនអាចខិតខំធ្វើអោយមានភាពយុត្តិធម៌នៅកន្លែងធ្វើការ និង ជាមួយរដ្ឋអំណាចស៊ីវិលបាន ។
- សូមទន្ទេញ ១ យ៉ូហាន ៣:១៨ ។
- សូមសរសេរអោយបានយ៉ាងតិចបីសកម្មភាព ដែលសមាជិកក្រុមជំនុំរបស់អ្នកត្រូវចាប់ផ្តើមធ្វើ ដើម្បីដោះស្រាយបញ្ហាដែលបណ្តាលមកពីភាពក្រខ្សត់ ឬ អយុត្តិធម៌នៅក្នុងសហ-គមន៍របស់អ្នក ។

ក្រុមជំនុំដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត បង្ហាញសេចក្តីស្រឡាញ់របស់ខ្លួនចំពោះមនុស្ស តាមរបៀបពីរយ៉ាង :

- ក្រុមជំនុំនោះផ្សព្វផ្សាយដំណឹងល្អប្រាប់មនុស្ស ដើម្បីអោយពួកគេថ្វាយខ្លួនទៅព្រះគ្រីស្ត ។
- ក្រុមជំនុំនោះជួយមនុស្សអោយចេះដោះស្រាយបញ្ហា ដោយអធិស្ឋានទូលសូមអោយព្រះជាម្ចាស់ជួយ ។

ពួកគ្រីស្តជនត្រូវបំរើមនុស្សម្នាក់ៗគ្រប់ផ្នែក គឺជួយទាំងខាងព្រលឹងវិញ្ញាណ ទាំងសេចក្តីត្រូវការខាងសម្ភារៈ និង សេចក្តីត្រូវការក្នុងសង្គមដែរ ។



ពួកគ្រីស្តជនបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកជិតខាងចំពោះ :

☐ តែព្រលឹងប៉ុណ្ណោះ ។

☐ បុគ្គលទាំងមូល (គ្រប់ផ្នែក) ។

ក្រុមជំនុំដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត កែប្រែសង្គមរបស់ខ្លួន

ក្នុងប្រវត្តិសាស្ត្រក្រុមជំនុំកន្លងមក «ការភ្ញាក់រលឹកខាងព្រលឹង-វិញ្ញាណដ៏ខ្លាំងក្លា (Great Spiritual Renewals)» ធ្វើអោយមានការកែប្រែក្នុងសង្គម និង ធ្វើអោយសង្គមមានភាពប្រសើរឡើង ។ កាលនោះ ពួកគ្រីស្តជនបានបំពេីបុគ្គលទាំងមូល គឺសេចក្តីត្រូវការគ្រប់ផ្នែករបស់មនុស្ស ។

នៅទ្វីបអឺរ៉ុប មុនសម័យកាល «កែទម្រង់របស់ពួកប្រូតេស្តង់ (Protestant Reformation)» រដ្ឋអំណាចរ៉ូម៉ាំងគ្រប់ជាន់ថ្នាក់ បានគ្រប់គ្រងលើអ្វីៗទាំងអស់ ថែមទាំងត្រួតត្រាលើមនសិការរបស់មនុស្សទៀតផង ។ ប៉ុន្តែ «ពួកអ្នកកែទម្រង់» ទាំងនោះ បានដោះស្រាយបញ្ហានេះ ដោយប្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

៣- ទឹកក្រខ្វក់ ជា :

☐ បញ្ហាសង្គមកិច្ច ដែលមានតែរដ្ឋាភិបាលប៉ុណ្ណោះដែលត្រូវដោះស្រាយ ។

☐ មូលហេតុបណ្តាលអោយមនុស្សស្លាប់ ដោយមិនសមហេតុផល ដូច្នេះ គ្រីស្តជនត្រូវចូលរួមដោះស្រាយបញ្ហានេះ ។

៤- បើសិនជាក្នុងសហគមន៍របស់ខ្លួនមានបញ្ហា ពួកគ្រីស្តជន ត្រូវ :

☐ គ្រាន់តែទៅព្រះវិហារ ។

☐ ធ្វើកិច្ចការដើម្បីជួយដោះស្រាយបញ្ហាទាំងនោះ ស្របទៅតាមគោលការណ៍ព្រះគម្ពីរ ។

☐ ខិតខំបំពេញតែសេចក្តីត្រូវការរបស់ខ្លួនផ្ទាល់ ។

© Project WorldReach © SEAN

ការប្រឡង (សំនួរសង្ខេបមេរៀន)

សូមគូសសញ្ញានេះ «✓» នៅនឹងចំលើយដែលត្រឹមត្រូវ ។

១- តួនាទីរបស់គ្រីស្តជនក្នុងសង្គម គឺ :

- ☐ បង្រៀនព្រះបន្ទូលព្រះជាម្ចាស់ ហើយទុកបញ្ហានៅក្នុងសង្គម និង ក្នុងរដ្ឋាភិបាល អោយពួកអ្នកមិនទាន់ជឿដោះស្រាយ ។
- ☐ ជួយបណ្តាជនឱ្យអាចដោះស្រាយបញ្ហាខាងសម្ភារៈ និងខាងសង្គមរបស់ពួកគេ ។

២- បើមានមនុស្សម្នាក់ថ្វាយខ្លួន និង ទទួលជឿព្រះយេស៊ូ នោះនឹងមានការផ្លាស់ប្រែ :

- ☐ តែលើខ្លួនអ្នកនោះផ្ទាល់ប៉ុណ្ណោះ ។
- ☐ ទាំងលើខ្លួនអ្នកនោះផ្ទាល់ ទាំងលើអស់អ្នកដែលនៅជុំវិញអ្នកនោះដែរ ។

ពួកគេពន្យល់មនុស្សថា ព្រះគ្រីស្តរំដោះយើងអោយមានសេរីភាពរួចពីអំពើបាបរបស់យើង តាមរយៈការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ។ ដូច្នេះ «ក្រុមជំនុំដែលផ្សាយដំណឹងល្អ (The Evangelical Church)» ក៏រីកចំរើនធំឡើងៗ ។

មនុស្សក៏មានសេរីភាពអាចថ្វាយបង្គំព្រះជាម្ចាស់បាន ស្របតាមមនសិការរបស់ពួកគេ ដោយធ្វើតាមសេចក្តីបង្រៀនរបស់ព្រះគម្ពីរ ។

នៅប្រទេសម៉ុកស៊ិច កុលសម្ព័ន្ធមួយក្រុម លែងស៊ូទ្រាំនឹងការប្រកាន់ព្វជសាសន៍ និង ការប្រកាន់វណ្ណៈក្នុងសង្គម ដែលពួកគេធ្លាប់ទទួលរងទៀតហើយ ។ ពួកគេក៏ចាប់ផ្តើមវាយប្រយុទ្ធ ដោយប្រើអំពើហិង្សា ។ «ក្រុមជំនុំផ្សព្វផ្សាយដំណឹងល្អ» បានទៅទាក់ទងជាមួយពួកគេ ហើយពន្យល់ប្រាប់ពួកគេអំពីសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត ។ ពួកអ្នកផ្សាយដំណឹងល្អនោះ បានប្រព្រឹត្តជាមួយពួកមនុស្សក្នុងកុលសម្ព័ន្ធនោះ ដោយសមភាព (ចាត់ទុកពួកគេជាមនុស្សស្មើភាពនឹងមនុស្សឯទៀត) ។ មនុស្សក្នុងកុលសម្ព័ន្ធរាប់ពាន់នាក់បានថ្វាយខ្លួនទៅព្រះគ្រីស្ត ហើយការថ្វាយខ្លួននេះ នាំអោយមនុស្សក្នុងកុលសម្ព័ន្ធនោះ អាចរក្សាសិទ្ធិរបស់ខ្លួន ដោយរបៀបអហិង្សា និង មានប្រសិទ្ធិភាព ។

គឺថាក្រុមជំនុំដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត ចេះដោះស្រាយបញ្ហាខាងព្រលឹងវិញ្ញាណ និង បញ្ហាសង្គម ដោយពឹងអាងលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រមទាំងដោយប្រើប្រាជ្ញា និង សេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់ប្រទានអោយពួកគេ ។

ឫសគល់នៃភាពក្រខ្សត់

ភាពក្រខ្សត់ ព្រមទាំងអំពើបាបគ្រប់យ៉ាង បណ្តាលមកពីការគិតតែប្រយោជន៍ផ្ទាល់ខ្លួន និង អយុត្តិធម៌ ហើយសុទ្ធតែអារក្សធ្វើអោយចំរើនឡើង ។



គាត់សំរេចចិត្តទុកចិត្តលើព្រះគ្រីស្ត ។ ដោយសារឫទ្ធានុភាពដែលគ្មានព្រំដែនរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គាត់ក៏មានជំនួយ ដើម្បីដោះស្រាយបញ្ហានេះ ។



© Project WorldReach © SEAN



ហេតុការណ៍ទាំងអស់នេះ បណ្តាលអោយកើតមានបញ្ហាជាបន្ត
បន្ទាប់ ។ ឧទាហរណ៍ ពួកអ្នកមានជួលអ្នកក្រអោយធ្វើការ ។
ពួកអ្នកមានច្រើនតែអោយប្រាក់ឈ្នួលតិចតួចណាស់ដល់អ្នកក្រ ។
អ្នកក្រក៏ក្លាយជាអ្នកលែងគិតគូរខ្វល់ខ្វាយអំពីអ្វីៗទាំងអស់ រួចគេ
អស់កំឡាំងទាំងកាយ ទាំងចិត្ត ។ បន្ទាប់មក ពួកគេក៏ធ្លាក់ខ្លួន
លួចប្លន់ថែមទៀតផង ។ ពួកអ្នកមានក៏ឆ្លៀតឱកាសនេះ គាប
សង្កត់អ្នកក្រអោយស្ថិតនៅក្រោមការសង្ស័យ និង ក្រោមការត្រួត
ត្រារបស់ពួកគេ ។ មានសេចក្តីអាក្រក់ផ្សេងៗទៀតមកបន្ថែមលើ
សេចក្តីអាក្រក់ទាំងនេះ ដូចជាការស្លប់ ការគុំគួន អំពើហិង្សា
ភាពលង់ខ្លៅ និង អសីលធម៌ ។ល។ ។

នៅពេលដែលមនុស្សជាប់ក្នុងបញ្ហាជាបន្តបន្ទាប់ទាំងអស់នេះ
អារក្សឆ្លៀតឱកាសដើម្បីបំផ្លាញគេ ។ អារក្សជំរុញអោយមនុស្ស
មានការសង្ស័យ ដើម្បីកុំអោយមនុស្សស្វែងរកដំណោះស្រាយតាម
ផ្លូវល្អ ។ អារក្សបណ្តុះអោយមានភាពអសីលធម៌ និង ភាពល្ងង់
ខ្លៅ ដើម្បីបណ្តាលអោយអ្នកក្រមិនអោយចំណីអាហារ ដែលមាន
ជីវជាតិដល់កូន ឬ មិនអោយកូនបានរៀនសូត្រត្រឹមត្រូវ រហូតដល់
ពួកគេមិនគិតគូរស្តារស្ថានភាពខ្លួនឱ្យបានប្រសើរឡើងទៀតផង ។
អារក្សធ្វើអោយពួកអ្នកក្រមិនទុកចិត្តគ្នាទៅវិញទៅមក ដើម្បីកុំឱ្យ
ពួកគេរួបរួមគ្នា ដោះស្រាយបញ្ហារបស់ពួកគេដោយសន្តិភាព ។



ពលរដ្ឋជាគ្រីស្តជន ខិតខំធ្វើឱ្យប្រទេសខ្លួនមានរដ្ឋាភិបាលត្រឹមត្រូវបំផុត ដោយមិនធ្វើឱ្យប៉ះពាល់អាក្រក់ដល់ក្រុមជំនុំរបស់ខ្លួនទេ ។ តើអ្នកគិតថា ហេតុអ្វីបានជាព្រះយេស៊ូថា÷ *«រាជ្យរបស់ខ្ញុំមិនមែននៅក្នុងលោកនេះទេ ?»* (យ៉ូហាន ១៨:៣៦) ។

នៅក្នុងសង្គម មនុស្សតែងតែមានបញ្ហាជានិច្ច ប៉ុន្តែ យើងអាចរកដំណោះស្រាយបាន :



ក្រុមជំនុំដែលជាព្រះកាយរបស់ព្រះគ្រីស្តនៅលើផែនដី មិនត្រូវចង
សម្ពន្ធមេត្រីជាមួយរដ្ឋាភិបាលមនុស្ស តាមរបៀបមួយ ដែលអាច
នាំអោយមានឥទ្ធិពលអាក្រក់ដល់ការស្តាប់បង្គាប់ព្រះជាម្ចាស់របស់
ក្រុមជំនុំនោះទេ ។ ព្រះគ្រីស្តមានបន្ទូលថា÷ *«រាជ្យរបស់ខ្ញុំ មិន
មែននៅក្នុងលោកនេះទេ »* (យ៉ូហាន ១៨:៣៦) ។ ព្រះអង្គ
មានព្រះបន្ទូលថា÷ *«អ្វីៗដែលជារបស់ព្រះចៅអធិរាជ ចូរថ្វាយ
ទៅព្រះចៅអធិរាជវិញទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់
ចូរថ្វាយទៅព្រះជាម្ចាស់វិញដែរ »* (ម៉ាថាយ ២២:២១) ។
ក្រុមជំនុំ និង រដ្ឋបំពេញមុខនាទីផ្សេងគ្នា ។ ក្រុមជំនុំធ្វើតាមព្រះ
បន្ទូល និង ព្រះហឫទ័យព្រះជាម្ចាស់ ។ បើរដ្ឋាភិបាលបំពេញ
មុខនាទីរបស់ខ្លួនបានត្រឹមត្រូវ រដ្ឋាភិបាលនោះនឹងថែរក្សាសុវត្ថិភាព
សន្តិភាព និង យុត្តិធម៌សំរាប់ពលរដ្ឋរបស់ជាតិសាសន៍ខ្លួនគ្រប់គ្នា
ដោយមិនគិតពីជំនឿសាសនាទេ ។ យើងប្រុងប្រយ័ត្ន កុំអោយ
ប្រព័ន្ធនយោបាយមួយ ឬ ក្រុមហ៊ុនជំនួញរបស់មនុស្សធ្វើផែនការ
អំពីរបៀបដែលយើងដើរតាមព្រះគ្រីស្ត ។

ឬសគល់ពិតនៃភាពក្រខ្សត់ គឺ :

☐ មូលហេតុទាក់ទងនឹងនយោបាយ និង សេដ្ឋកិច្ច ។

☐ មូលហេតុទាក់ទងនឹងសីលធម៌ និង ព្រលឹងវិញ្ញាណ ។

មូលហេតុដែលបណ្តាលអោយមានភាពក្រខ្សត់

សូមគូសសញ្ញា «✓» នេះ ក្នុងគំនូរបួនជ្រុង ដែលនៅក្បែរបញ្ជា
ដែលមាននៅក្នុងសហគមន៍ (សង្កាត់)របស់អ្នក ហើយដែលក្រុម
ជំនុំរបស់អ្នកអាចដោះស្រាយបាន :

☐ **ការអប់រំមានកំរិតទាប ។**

ដោយសារតែមនុស្សមួយចំនួន មិនបានទទួលការសិក្សាអប់រំ
គ្រប់គ្រាន់ ទើបមនុស្សរាប់ពាន់នាក់នៅក្នុងសហគមន៍ជា
ច្រើន មិនអាចរកការងារធ្វើបាន ។

☐ **អប៉ិយ៍ជំនឿ ។**

ដោយសារតែមិនបានដឹងពីដំណឹងល្អ ទើបមនុស្សជាច្រើន
យកសម្បត្តិបន្តិចបន្តួចដែលខ្លួនមាន ទៅចំណាយលើគ្រូ
ទាយ គ្រូចូលរូប គ្រូមន្តអាគម ។ល។ ។

☐ **ការកេងប្រវ័ញ្ចលើអ្នកក្រ និង ការមិនយកចិត្តទុកដាក់ចំពោះអ្នកក្រ ។**

នៅក្នុងពិភពលោកទាំងមូល មនុស្សចំនួន ២០ លាននាក់ បានស្លាប់ដោយអត់បាយជារៀងរាល់ឆ្នាំ ។ មនុស្សជាច្រើនលាននាក់ទៀត មានចំណីអាហារបរិភោគបានតិចតួចណាស់ ដែលបណ្តាលអោយពួកគេស្ទើរតែស្លាប់ដែរ ។ ប៉ុន្តែ នេះមិនមែនដោយសារក្នុងពិភពលោកខ្វះចំណីអាហារទេ ពីព្រោះក្នុងពិភពលោកមានចំណីអាហារគ្រប់គ្រាន់ ។ តែគឺបណ្តាលមកពីការបែងចែកចំណីអាហារមិនស្មើភាពគ្នា ការកេងយកប្រយោជន៍ពីអ្នកដទៃ និង ភាពអយុត្តិធម៌ក្នុងការងាររបស់អ្នកក្រ ។ ដើម្បីអាចផ្តត់ផ្គង់ទឹកស្អាត ចំណីអាហារ និង ការអប់រំដល់មនុស្សដែលខ្វះខាត ត្រូវចំណាយប្រាក់ច្រើនណាស់ ។ ប៉ុន្តែ បើប្រៀបធៀបនឹងចំនួនទឹកប្រាក់ ដែលគេចំណាយខ្លះខ្លាយ សំរាប់អំពើអាក្រក់ សំរាប់ប្រឆាំងនឹងឧក្រិដ្ឋកម្ម និង សំរាប់ទិញគ្រឿងសព្វាវុធ ដើម្បីធ្វើសង្គ្រាម នោះឃើញថាជាប្រាក់តិចតួចទេវិញទេ ។

សង្គម ។ អ្នកកសាងសន្តិភាព ស្មើជួនដំណោះស្រាយត្រឹមត្រូវ ដើម្បីបញ្ឈប់អំពើហិង្សា និង ធ្វើអោយមានសន្តិភាព និង ភាពស្មើគ្នា តាមដែលអាចធ្វើបាន ។

បើក្នុងសង្គមមានអំពើហិង្សា តើគ្រីស្តជនត្រូវធ្វើដូចម្តេច ?

☐ ពួនសំងំក្នុងផ្ទះ ។

☐ ចូលរួមធ្វើអំពើហិង្សា ។

☐ ធ្វើជាអ្នកកសាងសន្តិភាព ។

ពលរដ្ឋជាគ្រីស្តជន ដែលមានការទទួលខុសត្រូវល្អ បំពេញភារៈកិច្ចរបស់ខ្លួនក្នុងសហគមន៍ និង ជាតិសាសន៍ខ្លួន និង សហការយ៉ាងឈ្លាសវៃជាមួយរដ្ឋាភិបាលប្រទេសខ្លួន ។

- គាត់អធិស្ឋានអោយរដ្ឋអំណាច និង ប្រតិបត្តិតាមរដ្ឋអំណាច (រ៉ូម ១៣:១-៧, ១ ធីម៉ូថេ ២:១-៤) ។
- គាត់បោះឆ្នោតអោយបេក្ខជន ដែលទៀងត្រង់ជាងគេ ។
- គាត់ចូលរួមធ្វើសកម្មភាពក្នុងសហគមន៍ ឬ របស់រដ្ឋាភិបាល ដែលមនសិការរបស់គាត់យល់ថា ត្រូវធ្វើ ។

គ្រីស្តជនដែល**ធ្វើការងារ**ក្នុងរដ្ឋាភិបាល អាចបង្ហាញគំរូល្អ ភាពទៀងត្រង់ ឈ្លាសវៃ ស្មោះត្រង់ និង ការចេះគិតគូរពីមនុស្សទាំងអស់ ។

គ្រីស្តជនដែលធ្វើការក្នុងរដ្ឋាភិបាល ឬ ក្រសួងនានា ត្រូវការចេះព្រះគម្ពីរច្បាស់លាស់ និង ចេះធ្វើតាមការដឹកនាំរបស់ព្រះគម្ពីរ ។ ការអធិស្ឋានដោយស្មោះត្រង់ និង ការសិក្សាព្រះបន្ទូលព្រះជាម្ចាស់នឹងធ្វើអោយគេមានគ្រឹះរឹងមាំសំរាប់ការងាររបស់គេ ។ ការនេះជួយគេឱ្យអាចដោះស្រាយនឹងការគាបសង្កត់ និង អំពើពុករលួយដែលមាននៅក្នុងគ្រប់រដ្ឋាភិបាល ។

ព្រះជាម្ចាស់នឹងជំនុំជំរះរដ្ឋាភិបាល ដែលប្រើកំឡាំង ឬ អំណាចជ្រុល ។ ប៉ុន្តែ ពលរដ្ឋគ្រីស្តជនមិនត្រូវប្រើអំពើហិង្សាប្រឆាំងរដ្ឋាភិបាលទេ ទោះជានៅពេលដែលរដ្ឋាភិបាលធ្វើអំពើអាក្រក់ក៏ដោយ (ម៉ាថាយ ២៦:៥២, រ៉ូម ១២:១៧-១៨) ។

ព្រះជាម្ចាស់ត្រាស់ហៅអោយគ្រីស្តជន ធ្វើជាអ្នកកសាងសន្តិភាព (ម៉ាថាយ ៥:៩) ។ នេះមិនមែនបានន័យថា ពួកគេត្រូវមិនធ្វើអ្វី ឬ មិនគិតគូរពីអ្វីនោះទេ ។ ប៉ុន្តែ ត្រូវចូលរួមយ៉ាងសកម្ម ឈ្លាសវៃ និង មុតមាំ ដើម្បីផ្សះផ្សាមនុស្ស និង អោយមានយុត្តិធម៌ក្នុង

- **ទម្លាប់អាក្រក់ និង ការចោកប្រាស ។**

  រៀងរាល់ឆ្នាំ ទឹកប្រាក់រាប់ពាន់លានដុល្លារ ត្រូវចំណាយឥតប្រយោជន៍ទៅលើថ្នាំជក់ ។ គ្រូពេទ្យប្រមាណជឹងថា ថ្នាំជក់ជាមួលហេតុខ្លាំងជាងគេ ដែលបណ្តាលអោយមនុស្សស្លាប់ដោយសារជម្ងឺមហារីក និង ជម្ងឺសាហាវផ្សេងៗទៀត ។ ទឹកប្រាក់រាប់ពាន់លានដុល្លារ ត្រូវចំណាយសំរាប់ចាក់ភ្នាល់ល្បែងស៊ីសង ដែលជាហេតុបណ្តាលអោយគ្រួសាររាប់ចំនួនមិនអស់ នៅគ្រប់កន្លែងក្នុងពិភពលោក ត្រូវវេទនា គឺថាគេគ្មានចំណីអាហារហូបគ្រប់គ្រាន់ និង គ្មានថ្នាំពេទ្យព្យាបាល ។ ជារៀងរាល់ឆ្នាំ ទឹកប្រាក់ចំនួនរាប់ពាន់លានដុល្លារ ត្រូវគេលួចពីម្ចាស់ដើម ដោយលួចបន្លំតាមរបៀបហិរញ្ញវត្ថុ។ មានរបៀបលួចបន្លំ និង បោកប្រាសមនុស្ស នៅគ្រប់កន្លែងក្នុងពិភពលោកទាំងមូល ។

- **អំពើអាសអាភាស និង ពេស្យាចារ ។**

  អំពើអាសអាភាស ដូចជាទស្សនាវដ្តី ខ្សែភាពយន្តវីដេអូ ដែលអាសអាភាស ។ល។ ព្រមទាំងពេស្យាចារ ធ្វើអោយមនុស្សរាប់លាននាក់នៅក្នុងសហគមន៍ជាច្រើន ប្រព្រឹត្តកាមគុណថោកទាប ។

☐ **គ្រឿងញៀន និង ការប្រមឹកស្រាខុសច្បាប់ ។**

គ្រឿងញៀន និង ការប្រមឹកស្រាខុសច្បាប់ បំផ្លាញក្រុមគ្រួសារ និង ជីវិតមនុស្សជាច្រើននាក់ពីគ្រប់ស្រទាប់ក្នុងសង្គម ។

☐ **ការសូកប៉ាន់ ។**

ការសូកប៉ាន់ពួករដ្ឋអំណាច ធ្វើអោយសង្គមទាំងមូលពុករលួយ ។ ក្រុមហ៊ុនពាណិជ្ជកម្មធំៗខ្លះ គ្រប់គ្រងលើបនល្បែងស៊ីសង ការលក់ស្រា ការលក់ឆ្នោត អំពើអាសអាភាស ពេស្យាចារ ។ល។ ហើយក្រុមហ៊ុនទាំងអស់នេះច្រើនតែយកសំណូកច្រើនបំផុត ទៅសូកប៉ាន់សមាជិករដ្ឋាភិបាល ដើម្បីអោយរដ្ឋាភិបាលអនុញ្ញាតិអោយពួកគេអាចលក់គ្រឿងញៀន ឬ ប្រកបមុខរបរកេងប្រវ័ញ្ចផ្សេងៗទៀតបាន ។

☐ **ចំណាយខាងកងទ័ព ។**

គឺថា ចំណាយខាងកងទ័ពសំរាប់ធ្វើសង្គ្រាម ដែលមិនគួរធ្វើ ឬ សំរាប់ផ្គត់ផ្គង់ប្រាក់ដល់កងទ័ពដ៏ធំមួយ ដែលត្រូវការពារអ្នកកាន់អំណាចផ្តាច់ការម្នាក់អោយអាចកាន់អំណាចនោះរហូតបាន ។

ម្ចាស់ អាចធ្វើអ្វីៗបានច្រើន ដើម្បីធ្វើអោយរដ្ឋាភិបាលមានភាពប្រសើរឡើង ។

យើងអាចជួយដោយ**អធិស្ឋាន**អោយរដ្ឋអំណាច **ស្តាប់បង្គាប់**រដ្ឋអំណាច និង**ធ្វើការងារ**ក្នុងស្ថាប័នសាធារណៈ ជាគំរូល្អដល់អ្នកឯទៀត ។

១ ធីម៉ូថេ ២:១-៤ ដាស់តឿនអ្នកជឿអោយ**អធិស្ឋាន**សំរាប់អ្នកកាន់អំណាចទាំងអស់ ដើម្បីអោយបណ្តាជនអាចរស់នៅបានសុខក្សេមក្សាន្តគ្មានចលាចល និង មានជីវិតថ្លៃថ្នូរ ។

ទីតុស ៣:១ បង្រៀនយើងឱ្យ**ចេះស្តាប់បង្គាប់** និង គោរពអាជ្ញាធរ និង រដ្ឋអំណាច ហើយប្រុងប្រៀបប្រព្រឹត្តការល្អគ្រប់យ៉ាង បានន័យថា យើងត្រូវចុះចូលនឹងឪពុកម្តាយ គ្រូបង្រៀន និយោជក អ្នកដឹកនាំ រដ្ឋាភិបាល និង អ្នកទាំងអស់ដែលគ្រប់គ្រងលើយើង ។ បើសិនជាពួកគ្រីស្តជនគោរពអ្នកកាន់អំណាចនោះ ពួកគេនឹងធ្វើអោយពួកអ្នកកាន់អំណាចទាំងនោះ ចង់ដឹងពីដំណឹងល្អអំពីព្រះ-យេស៊ូ ។ ផ្ទុយទៅវិញ បើសិនជាគ្រីស្តជនមិនគោរពពួកអ្នកកាន់អំណាច នោះអ្នកកាន់អំណាច នឹងមិនចាប់អារម្មណ៍នឹងដំណឹងល្អព្រះយេស៊ូទេ ។ យើងគួរតែសរសើរគ្រូបង្រៀន ឬមន្ត្រីរាជការដែលធ្វើការងាររបស់ពួកគេ ដោយសុចរិត និង ស្មោះត្រង់ ។

ក្រៅពីការជួយដូចខាងលើនេះ យើងត្រូវគិតគូរពីយុត្តិធម៌ក្នុងសង្គម ប្រាក់ខែត្រឹមត្រូវ ការអប់រំ និង សុខភាពរបស់សហគមន៍ ។

គ្រីស្តជន :

- ☐ ធ្វើការងារសំរាប់តែប្រយោជន៍ដល់ខ្លួនឯង និង គ្រួសារខ្លួនប៉ុណ្ណោះ ។
- ☐ ខិតខំដោយសន្តិភាព ដើម្បីរកយុត្តិធម៌ និង អោយអ្នកធ្វើការបានប្រាក់ខែត្រឹមត្រូវ ។

ពួកគ្រីស្តជន និង រដ្ឋាភិបាល

ពួកគ្រីស្តជនជាប្រជាជនរបស់ស្ថានបរមសុខ (ភីលីព ៣:២០) ។ ប៉ុន្តែ ព្រះជាម្ចាស់ដាក់អោយយើងរស់នៅលើផែនដី ធ្វើជាអំបិល និង ពន្លឺនៅទីនេះ (ម៉ាថាយ ៥:១៣-១៦) ។ ដូចនេះ យើងក៏ជាប្រជាជនបណ្តោះអាសន្នរបស់លោកីយ៍នេះដែរ ។

ព្រះជាម្ចាស់បានតែងតាំងអោយមានរដ្ឋាភិបាលឡើង (រ៉ូម ១៣:១-៧) ។ ព្រះជាម្ចាស់តែងតាំងឱ្យមានអ្នកគ្រប់គ្រងល្អ ដូចជាលោកយ៉ូសែបនៅប្រទេសអេស៊ីប លោកដានីអែលនៅទីក្រុងបាប៊ីឡូន និង ស្តេចដាវីឌនៅប្រទេសអ៊ីស្រាអែល ។ នៅសម័យកាលផ្សេងៗទៀត រដ្ឋាភិបាលក្លាយទៅជាពុករលួយ ។ អ្នកបំរើព្រះជា-

- ☐ **ការបាត់បង់ព្រៃឈើ និង ការសឹកដី ។**

  ការប្រើប្រាស់ដីតាមទំនើងចិត្ត ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន ធ្វើអោយដីលែងមានជីវជាតិ ។

- ☐ **ការក្រខ្វក់ ។**

  គឺថា ទឹកក្រខ្វក់ដោយសារសារធាតុគីមី ឬ កាកសំណល់ដែលមនុស្សបញ្ចេញចោល ។ កុមារជាច្រើនត្រូវស្លាប់ដោយសារជម្ងឺរាគមួល ដែលបណ្តាលមកពីមេរោគអាមីប ឬ កូនព្រូនដែលនៅក្នុងទឹកក្រខ្វក់ ដោយសារមនុស្ស ឬ សត្វបានចម្លងមក ។

  គឺថា ខ្យល់អាកាសក្រខ្វក់ ដោយសារចំហាយពុលចេញពីរោងចក្រគ្រាប់បែក រោងចក្របន្សុត រថយន្ត ។ល។ ដែលបណ្តាលឱ្យមានជម្ងឺដល់ប្រព័ន្ធសរីរាង្គ ខាងការដកដង្ហើម និង ធ្វើអោយមានជម្ងឺភ្នែក ។

- ☐ **ការគ្មានសេរីភាព និង ការបៀតបៀន ។**

  គឺថា ការគ្មានសេរីភាព និង ការបៀតបៀនចំពោះពួកគ្រីស្តជន និង មនុស្សឯទៀត ដែលមានជំនឿ និង មានមតិផ្សេង ។

☐ **ការលែងលះ និង ការផិតក្បត់ ។**

ការលែងលះ និង ការផិតក្បត់ ជាគ្រោះកាចដែលបំផ្លាញក្រុមគ្រួសាររាប់ពាន់ នៅគ្រប់កន្លែងក្នុងពិភពលោកជារៀងរាល់ឆ្នាំ ។ ការលែងលះ និង ការផិតក្បត់ បណ្តាលអោយមានទុក្ខិតភាព និង ភាពក្រខ្សត់ ហើយបណ្តាលអោយកូនៗមានរបួសខាងផ្លូវចិត្ត និង មានការពិបាក ក្នុងការទាក់ទងជាមួយមនុស្សឯទៀត ពេញមួយជីវិត ។

មារសាតាំងចង់អោយយើងអស់សង្ឃឹម និង លែងមានសេចក្តីក្លាហាន ដោយសារយើងឃើញមានអំពើទុច្ចរិតច្រើនពេក នៅលើលោកនេះ ដើម្បីអោយយើងលែងខិតខំបំបាត់អំពើទុច្ចរិត ដោយសេចក្តីស្រឡាញ់ ។ ប៉ុន្តែ ១ យ៉ូហាន ៤:៤ ចែងថា÷ « *ដ្បិតព្រះអង្គដែលគង់នៅក្នុងអ្នករាល់គ្នា ទ្រង់មានអំណាចធំជាងម្ចាស់លោកីយ៍នេះទៅទៀត* » ។

សូមយើងអធិស្ឋាន ទូលសូមអោយព្រះជាម្ចាស់សំរេចព្រះហឫទ័យរបស់ព្រះអង្គ និង នាំព្រះរាជ្យរបស់ព្រះអង្គមកគ្រប់គ្រងលើផែនដីនេះ ។ សូមយើងផ្សាយដំណឹងល្អ ដើម្បីអោយបណ្តាជនកែប្រែចិត្តគំនិត ថ្វាយខ្លួន និង ចាប់ផ្តើមជីវិតថ្មី ហើយធ្វើការងារជួយមនុស្សអោយចេះដោះស្រាយបញ្ហារបស់ពួកគេខាងសម្ភារៈ ។ ធ្វើដូចនេះ យើងនឹងបានសំរេចជោគជ័យធំៗជាមិនខាន ។

ពួកគ្រីស្តជន ជាអ្នកចាត់ចែងទ្រព្យសម្បត្តិរបស់ព្រះជាម្ចាស់ ។ ពួកគេមានការទទួលខុសត្រូវនៅចំពោះព្រះជាម្ចាស់ លើរបៀបដែលពួកគេចាត់ចែងប្រាក់កាស ផលដំណាំ និង សម្ភារៈផ្សេងៗទៀត (ម៉ាថាយ ២៥:១៤-៣០) ។

អ្វីៗដែលយើងមានទាំងអស់ សុទ្ធតែមកពីប្រភពមួយសំខាន់ណាស់ ។ តើមកពីណា?

☐ ការខិតខំរបស់យើងផ្ទាល់ ។

☐ ព្រះជាម្ចាស់ជាព្រះអាទិករ ប្រទានអំណោយល្អៗគ្រប់យ៉ាងមកយើង ។

យើងត្រូវចាត់ចែងលើអ្វីៗគ្រប់យ៉ាង ដែលព្រះជាម្ចាស់បានប្រទានអោយយើង ដើម្បីប្រើប្រាស់តាមរបៀបដែលថ្វាយសិរីរុងរឿងទៅព្រះអង្គ ។ ដោយហេតុនេះហើយ ទើបយើងត្រូវបង់ថ្លៃវិក្កយប័ត្រដោយទៀងទាត់ តាមពេលវេលា និង ដោយអំណរ ។

គឺថា ត្រូវធ្វើជាអ្នកបំរើដល់សហគមន៍ មិនមែនគ្រាន់តែទាញផលប្រយោជន៍ពីសហគមន៍ប៉ុណ្ណោះទេ ។ យើងជួយអ្នកខ្វះខាតបង្កើតប្រភពការងារ (ជួយមនុស្សអោយមានការងារធ្វើ) ជួយសង់ផ្ទះអោយអ្នកក្រ បង្កើតមណ្ឌលបណ្តុះបណ្តាល ។ល។ ដើម្បីអោយយុវជន និង អ្នកធ្វើការអាចរីកចំរើនបាន ។

☐ ទៅថ្ងៃមុខ ម្ចាស់បំណុលគ្មានលុយអោយអ្នក ឬ អ្នកផ្សេងខ្ចីទៀតទេ ។

☐ នេះជាការបោកប្រាសយកលុយពីអ្នកដទៃ ។

ការខ្ចីលុយ ហើយដឹងថា អ្នកនឹងមិនសងលុយគេវិញ ជាការបោកប្រាសផង លួចផង ។ ការធ្វើដូចនេះ បំផ្លាញទំនាក់ទំនងជាមួយមនុស្សឯទៀត និង រំលោភលើការជឿទុកចិត្តរបស់អ្នកឯទៀត ។



ព្រះយេស៊ូគ្រីស្តបង្គាប់យើង ឱ្យស្រឡាញ់អ្នកជិតខាងរបស់យើង ដូចជាអ្នកស្រុកសាម៉ារី ដែលមានចិត្តសប្បុរស ជួយជនជាតិយូដាដែលត្រូវចោរប្លន់ ។ តាមការពិត ព្រះយេស៊ូចង់បញ្ជាក់ថា បើយើងមិនប្រតិបត្តិតាមសេចក្តីបង្គាប់នេះ ដែលឱ្យយើងបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះអ្នកជិតខាងរបស់យើងទេ យើងមិនមែនជាគ្រីស្តជនពិតទេ (លូកា ១០:២៥-៣៧, ម៉ាថាយ ២៥:៣១-៤៦) ។ យើងអាចស្រឡាញ់ និង ចេះជួយអ្នកដទៃ ដោយសារយើងស្រឡាញ់ព្រះអម្ចាស់យេស៊ូគ្រីស្ត និង ឧស្សាហ៍ទាក់ទងផ្ទាល់ជាមួយព្រះអង្គ ។

តើនៅក្នុងសហគមន៍របស់អ្នក នៅមានសេចក្តីត្រូវការអ្វីផ្សេងទៀតដែលអ្នក និង ក្រុមជំនុំរបស់អ្នក ត្រូវតែជួយ ? (ក្រៅពីមូលហេតុដែលបណ្តាលឱ្យមានភាពក្រខ្សត់ ដែលអ្នកបានគូសសញ្ញានៅទំព័រមុនៗ) ។

ព្រះជាម្ចាស់តែងតែប្រើប្រជារាស្ត្ររបស់ព្រះអង្គ អោយដោះស្រាយ ភាពក្រខ្សត់ និង អយុត្តិធម៌ ។ ភាពក្រខ្សត់ និង ទុគ៌តភាពដែលខ្លាំងជាងគេបង្អស់ មាននៅប្រទេស ដែលជំណឹងល្អមិនទាន់ទៅដល់ ឬ ដែលក្រុមជំនុំមិនទាន់ប្រតិបត្តិតាមសេចក្តីបង្គាប់ ដែលឱ្យស្រឡាញ់អ្នកជិតខាងខ្លួនដូចជាខ្លួនឯង ។ នៅពេលដែលយើងប្រតិបត្តិតាមព្រះបន្ទូលព្រះជាម្ចាស់ យើងនឹងធ្វើអោយលែងមានអបិយ៍ជំនឿ ភាពល្ងង់ខ្លៅ ការកេងប្រវ័ញ្ច អាត្មានិយម និង ការបោកប្រាស ដោយធ្វើឱ្យមានសេចក្តីស្រឡាញ់ ចិត្តសប្បុរស និង ភាពយុត្តិធម៌វិញ ។ ព្រះជាម្ចាស់ចង់អោយយើងគ្រប់គ្នាបានទទួលព្រះពរក្នុងគ្រប់ផ្លូវ (៣ យ៉ូហាន ជំពូក ២) ។

ការដែលយើងកែប្រែចិត្តគំនិតពិតប្រាកដ នឹងនាំអោយទាំងអ្នកជឿ ទាំងសហគមន៍កែប្រែ និង មានព្រះពរ ។

នៅពេលដែលយើងថ្វាយខ្លួនទៅព្រះគ្រីស្តហើយ ការកែប្រែចិត្តចេញពីអំពើបាប មិនមែនគ្រាន់តែបានន័យថា លែងមានទម្លាប់មិនល្អ ដូចជាលែងញៀនស្រានោះទេ ប៉ុន្តែ ព្រមជាមួយនេះ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងធ្វើការក្នុងយើង បណ្តាលអោយយើងមានជំនឿថ្មី គំនិតថ្មី បំណងថ្មី និង ទម្លាប់ថ្មីក្នុងព្រះយេស៊ូគ្រីស្ត ។

អ្នកជំនួញគ្រីស្តជនត្រូវចាត់ចែងមុខជំនួញរបស់ខ្លួន ដោយកោតខ្លាចព្រះជាម្ចាស់ ។ គាត់គោរព និង ស្មោះត្រង់ចំពោះបុគ្គលិករបស់គាត់ និង អតិថិជន (អ្នកទិញ) និង បុគ្គលិករដ្ឋអំណាចដែលទាក់ទងនឹងមុខជំនួញរបស់គាត់ ។ គាត់មិនត្រូវកេងប្រវ័ញ្ចអ្នកដទៃយកផលប្រយោជន៍ដើម្បីខ្លួនឯងទេ ។ គាត់ដឹកនាំមុខជំនួញគ្រប់យ៉ាងរបស់គាត់ ស្របទៅតាមច្បាប់សីលធម៌ និង ច្បាប់ការងារ ។ របៀបផ្សាយពាណិជ្ជកម្ម របៀបលក់ដូរ របៀបដាក់តំលៃរបស់គាត់ ត្រឹមត្រូវ និង ទៀងត្រង់ ។ មុខជំនួញ អង្គការ ឬ ក្រុមហ៊ុនដែលទៀងត្រង់ មានប្រយោជន៍ដល់សហគមន៍ទាំងមូល ។

ការមិនទៀងត្រង់ក្នុងរឿងដែលទាក់ទងនឹងប្រាក់កាស បំផ្លាញសង្គម និង សេដ្ឋកិច្ច ។ ការបោកប្រាស ការលួចបន្លំ ការរំលោភលើកិច្ចសន្យា សំណូក និង ការចងការប្រាក់យកការខ្ពស់ៗ មានឥទ្ធិពលអាក្រក់លើទំនាក់ទំនង និង កិច្ចសន្យាមុខជំនួញ ក្នុងសង្គមនិមួយៗ ដែលនាំឱ្យមនុស្សនៅក្នុងសហគមន៍ទទួលឥទ្ធិពលអាក្រក់ (ខ្វះប្រយោជន៍) ។ ចំពោះរឿងប្រាក់-កាស គ្រីស្តជនតែងតែគោរពពាក្យសំដីខ្លួនជានិច្ច ។

បើអ្នកខ្ចីលុយគេ ហើយប្រាប់ម្ចាស់បំណុលថា អ្នកធានាសងគេវិញដាច់ខាត ប៉ុន្តែ ក្នុងចិត្តអ្នក អ្នកគ្មានបំណងសងប្រាក់ទៅគេវិញ នោះជាការលួចគេហើយ ។ ព្រោះអ្វី ? ។

© Project WorldReach © SEAN

បុគ្គលិកជាគ្រីស្តជន ត្រូវឧស្សាហ៍ព្យាយាមធ្វើការងារ ដោយទៀងត្រង់ ។

ម៉្យាងទៀត ចៅហ្វាយនាយជាគ្រីស្តជនត្រូវផ្តល់ប្រាក់ខែត្រឹមត្រូវដល់បុគ្គលិក តាមដែលបុគ្គលិកត្រូវបាន (១ ធីម៉ូថេ ៥:១៨) ។ ព្រះជាម្ចាស់ដាក់ទោសចៅហ្វាយនាយ ដែលកេងប្រវ័ញ្ចលើបុគ្គលិករបស់ខ្លួន (យ៉ាកុប ៥:១-៦) ។ លើសពីនេះទៅទៀត ចៅហ្វាយនាយ ត្រូវផ្តត់ផ្តង់អោយមានបរិយាកាសការងារស្អាត និងមានសុវត្ថិភាពសំរាប់បុគ្គលិករបស់ខ្លួន ។

និយោជក និយោជិត (ចៅហ្វាយ និង អ្នកធ្វើការ) អ្នកជំនួញកម្មករ កសិករ និស្សិត គ្រូគង្វាល និង គ្រីស្តទូត ត្រូវធ្វើការ ទាំងអស់គ្នាដើម្បីថ្វាយសិរីល្អទៅព្រះជាម្ចាស់ (កូឡូស ៣:១៧, ៣:២៣) ។

ចៅហ្វាយជាគ្រីស្តជន ត្រូវ :

- ☐ ខិតខំអោយមានបានយ៉ាងឆាប់រហ័ស ។
- ☐ គ្រប់គ្រងមុខជំនួញរបស់ខ្លួន ដូចជាបំរើព្រះជាម្ចាស់ និងបំរើមនុស្សឯទៀត ។
- ☐ ភរ និង លួចបន្លំ ដូចអ្នកដទៃដែរ ។

ការកែប្រែអាកប្បកិរិយាគ្រប់យ៉ាង រួមមាន :

- ការដឹងច្បាស់ថា ត្រូវទុកអ្វីជាទីមួយ ជាពិសេស ទុកព្រះ-រាជ្យរបស់ព្រះជាម្ចាស់ជាទីមួយជានិច្ច (ម៉ាថាយ ៦:៣៣) ។
- ការថែរក្សាក្រុមគ្រួសាររបស់អ្នកអោយបានល្អ (១ ធីម៉ូថេ ៥:៨) ។
- ការអោយថ្លៃឈ្នួលសមរម្យ និង មានភាពយុត្តិធម៌ (យ៉ាកុប ៥:៤) ។
- ការចែកចាយជាមួយអ្នកដទៃ និង មានចិត្តអាណិតអាសូរ (ហេប្រឺ ១៣:១៦) ។
- ការចុះចូលនឹងរដ្ឋអំណាច (រ៉ូម ១៣:១-២) ។
- ការបង់ពន្ធដារ (រ៉ូម ១៣:៦-៧) ។
- ការធ្វើការងារដោយចិត្តទៀងត្រង់ (អេភេសូ ៤:២៨) ។
- ការទទួលខុសត្រូវចំពោះការប្រើ និង ចាត់ចែងធនធានធម្មជាតិ (កំណើតពិភពលោក ១:២៨-៣១) ។



នៅពេលដែលមនុស្សកែប្រែចិត្តគំនិតចេញពីអំពើបាប លទ្ធផល គឺ :

- ☐ មានតែអ្នកកែប្រែចិត្តគំនិតនោះ ដែលនឹងមានជីវិតប្រសើរជាងមុន ។
- ☐ ទាំងអ្នកកែប្រែចិត្តគំនិតនោះ ទាំងពួកអ្នកជិតខាងរបស់គេ នឹងមានជីវិតប្រសើរជាងមុន ។

បើក្រុម ឬ ជាតិសាសន៍ណាមួយ កេងប្រវ័ញ្ចក្រុម ឬ ជាតិសាសន៍មួយទៀត ក៏បណ្តាលអោយមានភាពក្រខ្សត់ដែរ ។ ប៉ុន្តែ នៅក្នុងព្រះគ្រីស្ត ជាតិសាសន៍នានា ឬ ក្រុមមនុស្សនានារួមគ្នាជារូបកាយតែមួយ (អេភេសូ ២:១៤-១៦) ។

ពួកគ្រីស្តជន និង ការងារ

ចាប់តាំងពីដើមដំបូងបង្អស់ ព្រះជាម្ចាស់ប្រទានអោយមនុស្សធ្វើការងារ (កំណើតពិភពលោក ២:១៥) ។ សុភាសិត ៦:៦ ប្រៀបធៀបមនុស្សខ្ជិលជាមួយស្រមោច : *«ភ្នែកំជិលអើយ ចូរទៅមើលស្រមោច ហើយពិចារណាអំពីការរស់នៅរបស់វា រួចយកមេរៀនពីវាទៅ !»* ។ លោកប៉ូលទូន្មានអោយគ្រីស្តជនគ្រប់គ្នាធ្វើការងារ ដើម្បីផ្គត់ផ្គង់គ្រួសារខ្លួនឯង ដើម្បីអោយអ្នកជំទៃគោរព និង ដើម្បីកុំឱ្យរស់ដោយសារអ្នកជំទៃ (១ ថេស្សាឡូនិក ៤:១១-១២, ២ ថេស្សាឡូនិក ៣:៧-១៣) ។

ពួកគ្រីស្តជន :

- ☐ ត្រូវពឹងលើក្រុមជំនុំអោយផ្គត់ផ្គង់ ។
- ☐ ត្រូវធ្វើការដើម្បីចិញ្ចឹមជីវិត ដោយកម្លាំងញើសឈាមខ្លួនឯង ។



ភាពក្រខ្សត់ជាច្រើន បណ្តាលមកពីការប្រកាន់ពូជសាសន៍ និង ប្រកាន់វណ្ណៈក្នុងសង្គម ។ ពួកគ្រីស្តជនត្រូវគោរពមនុស្ស ដែលមានវប្បធម៌ផ្សេង និង ដែលជាជាតិសាសន៍ផ្សេង ទោះបីជាអ្នកទាំងនោះមិនជឿលើព្រះយេស៊ូក្តី ។ ក្នុងព្រះសហគមន៍របស់ព្រះជាម្ចាស់ មានអ្នកជឿជាជាតិសាសន៍ផ្សេងៗគ្នា តែពួកគេទាំងអស់បានរួមគ្នាមកជាអង្គតែមួយក្នុងព្រះគ្រីស្តយេស៊ូ (កាឡាទី ៣:២៨) ។

តែងតែមានជំលោះជារឿយៗរវាងជនជាតិស្បែកស និង ជនជាតិស្បែកខ្មៅ រវាងអ្នកសង្គមនិយម និង អ្នកមូលធននិយម (សេរីនិយម) រវាងជនជាតិអារ៉ាប់ និង ជនជាតិយូដា រវាងកូនកាត់ និង ជនជាតិដើម រវាងចៅហ្វាយ និង កម្មករ ។ល។ ។

ការដែលយើងថ្វាយខ្លួនទៅព្រះគ្រីស្ត មានឥទ្ធិពលល្អណាស់ទៅលើសហគមន៍ទាំងមូល ។



អ្នកក្រត្រូវអប់រំខ្លួនឯង និង សន្សំប្រាក់ ទោះជាបន្តិចម្តងៗក៏ដោយ ដើម្បីអាចអោយកូនៗទៅរៀន និង ឱ្យចំណីអាហារកូនៗបរិភោគប្រសើរជាងមុន ព្រមទាំងដើម្បីអាចជួសជុលផ្ទះរបស់ខ្លួនបាន ។ល។...។ ពួកគ្រីស្តជនត្រូវធ្វើជាគំរូល្អ អំពីរបៀបរស់នៅដល់មនុស្សឯទៀតគ្រប់ៗរូប (ម៉ាថាយ ៥:១៣-១៦) ។



មនុស្សគ្រប់គ្នាសុទ្ធតែដឹងថា ការប្រមឹកស្រាមានឥទ្ធិពលអាក្រក់លើរូបកាយ ។ ប៉ុន្តែ ការអោយទឹកក្រខ្វក់ទៅកុមារផឹក ក៏នាំឱ្យខូចសុខភាពកុមារដែរ ពីព្រោះកុមារមិនដឹងអី ហើយមិនដឹងថាក្នុងទឹកក្រខ្វក់នោះ មានមេរោគអាមីប និង កូនព្រូនដែលនាំអោយខូចសុខភាពនោះឡើយ ។

របៀបសំអាតទឹក :

ដើម្បីសំលាប់មេរោគក្នុងទឹក ការប្រសើរបំផុត គឺដាំទឹកទុកអោយពុះដប់នាទី ។ របៀបម្យ៉ាងទៀត គឺដាក់ទឹកក្នុងកែវ ឬ ដបថ្លាមានគម្រប រួចយកទៅដាក់ហាលថ្ងៃរយៈពេលពីរថ្ងៃពេញ ។

អាចក្រឡុកទឹក ដើម្បីអោយមានខ្យល់អុកស៊ីសែន ចូលទៅក្នុងទឹក ។ ពន្លឺថ្ងៃអាចសំលាប់មេរោគ ដែលបណ្តាលអោយមានជម្ងឺចំនួន ៩៩,៩% ។ បើសិនជាទឹកល្អក់ ដំបូងត្រូវត្រងទឹកនោះ ដោយជីខ្សាច់សិន ឬ ទុកអោយកករភក់រងធ្លាក់ទៅបាតសិន សឹមចាក់ទឹកចូលទៅក្នុងកែវ ឬ ដបសំរាប់ដាក់ហាលថ្ងៃ ។

សេចក្តីស្រឡាញ់របស់យើងចំពោះគ្រីស្តជន ដែលបានធ្វើខុស យើងត្រូវកែតម្រង់គាត់ដោយសុភាពរាបសា ដូចមានរៀបរាប់នៅក្នុង កាឡាទី ៦:១ ។

ឧទាហរណ៍មួយទៀត : អ្នកជឿខ្លះបានទទួលស្គាល់ថា ការផឹកស្រាច្រើននាំអោយខូចសុខភាព ដូច្នេះ ពួកគេក៏ឈប់ផឹកស្រា ។ ប៉ុន្តែ បើអ្នកទាំងនោះផឹកទឹកក្រខ្វក់នោះ ពួកគេនៅតែធ្វើបាបលើរូបកាយដដែល ។ ពួកអ្នកដែលជឿលើព្រះយេស៊ូ មានបំណងចង់មានសុខភាពល្អ និង ចង់ថែរក្សារូបកាយរបស់ខ្លួន ។ ដូច្នេះ ពួកគេដាំទឹកអោយពុះទុកហូប និង ការពារអណ្តូងទឹក និង ប្រភពទឹកកុំអោយក្រខ្វក់ ។

បើការបំផ្លាញខ្លួនឯងដោយប្រមឹកស្រា ជាអំពើបាប តើការធ្វេសប្រហែស ដែលបណ្តោយអោយកូនៗរបស់ខ្លួនផឹកទឹកក្រខ្វក់ ជាអំពើបាបដូចគ្នានេះដែរឬទេ ?

☐ ពិតជាអំពើបាបមែន ។

☐ មិនមែនជាអំពើបាបទេ ។

សំណួរ : អ្នកជឿដែលក្រីក្រ ត្រូវ :

☐ ទទួលភាពក្រខ្សត់ មិនរើបំរះ ។

☐ ធ្វើការងារ និង សន្សំប្រាក់តាមលទ្ធភាពរបស់ខ្លួន ។

ព្រះជាម្ចាស់បានសន្យាថា នឹងបំពេញសេចក្តីត្រូវការរបស់យើង (លូកា ១២:២៩-៣១) ។



© Project WorldReach © SEAN

អ្នកជឿដែលមានប្រាជ្ញា ជាអ្នកចេះបំរើដ៏ល្អក្នុងគ្រប់ផ្នែក ដែលគាត់ទទួលខុសត្រូវ ។



ពួកគ្រីស្តជន ក៏ត្រូវថ្វាយទៅព្រះជាម្ចាស់យ៉ាងតិច មួយភាគដប់នៃចំណូលរបស់ខ្លួនដែរ ។ បើធ្វើដូចនេះ ពួកគេនឹងទទួលព្រះពរដ៏បរិបូរពីព្រះជាម្ចាស់ (ម៉ាឡាគី ៣:១០-១២) ។ ក្រុមជំនុំត្រូវថែរក្សាសម្ភារៈទាំងឡាយ ដែលព្រះជាម្ចាស់ប្រទានអោយ ហើយត្រូវធ្វើយ៉ាងណា ណែនាំសមាជិករបស់ខ្លួនអោយធ្វើជាមនុស្សត្រឹមត្រូវ និង ទៀងត្រង់ ។ ក្រុមជំនុំផ្ទាល់ក៏ត្រូវសុចរិត និង ទៀងត្រង់ក្នុងគ្រប់កិច្ចការដែរ ។

ឧទាហរណ៍ : សមាជិកក្រុមជំនុំម្នាក់ បានយកព្រះគម្ពីរជាច្រើនពីក្រុមជំនុំរបស់គាត់ ទៅលក់ឱ្យមនុស្សដែលមិនមែននៅក្នុងក្រុមជំនុំគាត់ ហើយគាត់ទុកលុយនោះសំរាប់ខ្លួនឯង ។ ក្រុមជំនុំរបស់គាត់ដឹងអំពីបញ្ហានេះ តែមិនធ្វើអ្វីសោះ ។ ក្រោយមក គាត់លួចរបស់ពីសមាជិកម្នាក់នៃក្រុមជំនុំ ពេលនោះទើបក្រុមជំនុំប្រៀនប្រដៅគាត់ ។

ហេតុអ្វីបានជាក្រុមជំនុំមិនប្រៀនប្រដៅតាំងពីដំបូង កាលគាត់លួចព្រះគម្ពីរ ? ដោយសារតែក្រុមជំនុំមិនបានកែតម្រូវសមាជិកនោះ នាំអោយអ្នកដទៃស្មានថា ក្រុមជំនុំមិនយកចិត្តទុកដាក់ចំពោះការមិនទៀងត្រង់របស់សមាជិក ។ ហេតុនេះហើយបានជាសមាជិកនោះ នៅតែធ្វើបាបទៀត ហើយរឿងរបស់គាត់មិនត្រឹមតែនាំឱ្យអ្នកជឿថ្មីជំពប់ដួលប៉ុណ្ណោះទេ តែក្លាយជារឿងអាស្រូវ ដែលគេឯងដឹងឮគ្រប់គ្នាទៀត ។

នៅពេលដែលយើងឃើញអំពើបាប យើងត្រូវទទួលស្គាល់ថា ការប្រព្រឹត្តនោះ ជាអំពើបាបមែន ។ លើសពីនេះទៅទៀត យើងត្រូវហ៊ានព្រមានអស់អ្នកដែលធ្វើខុសនោះ ហើយណែនាំអ្នកទាំងនោះអោយកែប្រែចិត្តគំនិត ។ បើមានសមាជិកលួចរបស់គេ នោះត្រូវសងរបស់ដែលគេបានលួចទៅឱ្យម្ចាស់ដើមគេវិញ ។ ដើម្បីបង្ហាញ